ACCESS 2
Sustainable quality services for all

Australian Aid

ព្រឹត្តិបត្រព័ត៌មានខេត្ត

ACCESS 2 ក្នុងខេត្តកំពង់ចាម

កម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី២

ព័ត៌មានសង្ខេបអំពីខេត្តកំពង់ចាម

១២%
នៃស្ត្រីធ្លាប់ទទួលរងអំពើហិង្សាពីដៃគូស្និទ្ធស្នាល[1]

១៩,៣%
នៃចំនួនប្រជាជនមានពិការភាពក្នុងទម្រង់ណាមួយ[2]

៧
ដៃគូ ACCESS 2 កំពុងធ្វើការនៅក្នុងខេត្តនេះ

[1] ស្ត្រីដែលធ្លាប់មានដៃគូ អាយុពី១៥ ដល់៤៩ឆ្នាំ ធ្លាប់បានទទួលរងអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ឬផ្លូវអារម្មណ៍នៅដំណាក់កាលណាមួយក្នុងជីវិតរបស់ពួកគេ។ យោងតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២។

[2] តាមរបាយការណ៍បានឱ្យដឹងថា ក្រុមប្រជាជនដែលមានអាយុចាប់ពី៥ឆ្នាំឡើងទៅ មានការលំបាកក្នុងកម្រិតណាមួយ (មានការលំបាកខ្លះ មានការលំបាកខ្លាំង ឬមិនអាចធ្វើអ្វីបានសោះ)។ យោងតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០១៤ និងឆ្នាំ២០២១-២០២២

តើ ACCESS 2 ធ្វើអ្វីខ្លះក្នុងខេត្តកំពង់ចាម



កម្មវិធី ACCESS 2 កំពុងអនុវត្តសកម្មភាពនៅខេត្តកំពង់ចាម ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានសេវាដែលមានការសម្របសម្រួល និងបរិយាបន្នសម្រាប់អ្នកនៅរស់រានពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) និងជនមានពិការភាពឱ្យទទួលបានការគាំទ្រទាន់ពេលវេលា និងប្រកបដោយគុណភាព ស្របតាមអាទិភាពជាតិ។ ការគាំទ្ររបស់អូស្ត្រាលីបានភ្ជាប់មន្ទីរនានានៅថ្នាក់ខេត្ត សេវាសុខាភិបាល និងសង្គមស៊ីវិលនៅក្នុងផ្នែកការងារទាំងបីរបស់កម្មវិធីនៅក្នុងខេត្តនេះ។



ការសម្របសម្រួល គឺជាមូលដ្ឋានគ្រឹះនៃវឌ្ឍនភាពនេះ។ គណៈកម្មាធិការសម្របសម្រួលថ្នាក់ខេត្ត បានលើកទឹកចិត្តអាជ្ញាធរថ្នាក់ក្រោមជាតិ និងដៃគូអនុវត្តឱ្យធ្វើការរួមគ្នា។ រីឯ ក្រុមប្រឹក្សាសកម្មភាពជនពិការខេត្ត និងក្រុមការងារឆ្លើយតបGBV អនុវត្តផែនការជាតិនៅថ្នាក់ស្រុក និងឃុំ។ ប្រព័ន្ធបញ្ជូនបន្តដែលត្រូវបានពង្រឹង បានភ្ជាប់បន្ទប់ផ្តល់ប្រឹក្សាយោបល់ផ្នែកGBV នៅឃុំ ក្រុមការងារថ្នាក់ស្រុក និងសេវានៅតាមមន្ទីរពេទ្យបង្អែកខេត្ត។

ខេត្តនេះបង្ហាញលទ្ធផលដែលកើតចេញពីការចូលរួមជាបន្តបន្ទាប់។ កន្លែងផ្តល់សេវាចម្រុះសម្រាប់អ្នកនៅរស់រានមានជីវិតពី GBV បានស្វាគមន៍ដំណើរទស្សនកិច្ចសិក្សាពីខេត្តផ្សេងៗ ខណៈជនមានពិការភាពបច្ចុប្បន្នបានចូលរួមជាមួយគណៈ កម្មាធិការឃុំ សង្កាត់នៅទូទាំងខេត្ត ហើយសេវាការព្យាបាលដោយចលនា (PT) កំពុងតែពង្រីកនៅមន្ទីរពេទ្យបង្អែកខេត្ត។

ការចារអារម្មណ៍ដែលកំពុងអនុវត្តនៅខេត្តកំពង់ចាម

- អំពើហិង្សាទាក់ទងនឹងយេនឌ័រ
- បរិយាបន្នពិការភាព
- ការស្តារលទ្ធភាពពលកម្ម

លទ្ធផលសម្រេចបាននៅខេត្តកំពង់ចាម គិតត្រឹមខែមិថុនា ឆ្នាំ២០២៦

១.៩៥៧ នាក់
បានទទួលសេវានៅផ្នែក PT ដែលទើបបង្កើតថ្មីក្នុងមន្ទីរពេទ្យខេត្ត

១៩.១១៦ នាក់
ជាជនមានពិការភាព ត្រូវបានកំណត់អត្តសញ្ញាណ ក្នុងនោះ ៣.៣០៤ នាក់ បានទទួលសេវាពីកម្មវិធីកញ្ចប់គ្រួសារ

៤៤១ នាក់
ជាអ្នកនៅរស់រានពីGBV បានទទួលការគាំទ្រ រួមទាំងការប្រឹក្សាយោបល់ និងតំណាងផ្នែកច្បាប់ដោយឥតគិតកម្រៃ

តើយើងធ្វើការជាមួយអ្នកណាខ្លះក្នុងខេត្តកំពង់ចាម

ដៃគូជារដ្ឋបាលខេត្ត

- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត
- មន្ទីរកិច្ចការនារីខេត្ត
- មន្ទីរសុខាភិបាលខេត្ត
- ក្រុមប្រឹក្សាសកម្មភាពជនពិការខេត្ត
- ក្រុមការងារឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ
- មូលនិធិជនពិការ
- គណៈកម្មាធិការឃុំ សង្កាត់ ទទួលបន្ទុកការងារស្ត្រី និងកុមារ (គ.ក.ន.ក)

ដៃគូអនុវត្ត និងសង្គមស៊ីវិល

- អង្គការជនពិការកម្ពុជា
- អង្គការ Handicap International (HI)
- អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC)
- អង្គការ PAfID
- អង្គការចិត្តសង្គម អន្តរវប្បធម៌កម្ពុជា (TPO)
- អង្គការ UNICEF, UNFPA និង UN Women
- អង្គការតំណាងជនមានពិការភាព
- វេទិកាស្ត្រីមានពិការភាព

សកម្មភាពចម្បងៗក្នុងខេត្តកំពង់ចាម

ផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ

- គាំទ្រក្រុមការងារឆ្លើយតប GBV ចំនួន៧ក្រុម (ថ្នាក់ខេត្ត១ និងថ្នាក់ស្រុក៦) និងបណ្តុះបណ្តាលសមាជិកចំនួន២៧១នាក់ អំពីការផ្តល់ប្រឹក្សា ការបញ្ជូន និងការគាំទ្រផ្នែកច្បាប់
- ពង្រីកបន្ទប់ប្រឹក្សាយោបល់ផ្នែក GBV ដែលរក្សាការសម្ងាត់ នៅតាមសាលាឃុំ ដោយក្នុងនោះមាន១០បន្ទប់ កំពុងដំណើរការ
- ផ្តល់ការគាំទ្រផ្នែក GBV បានចំនួន៤៤១ករណី ជាមួយនឹងការផ្តល់សេវាចំនួន៨៨៨ សេវា

ផ្នែកបរិយាបន្នពិការភាព

- គាំទ្រការកំណត់អត្តសញ្ញាណជនមានពិការភាពនៅទូទាំងខេត្ត ដោយបានវាយតម្លៃមនុស្សចំនួន ១៩.១១៦ នាក់ ហើយក្នុងនោះ ជនមានពិការភាពចំនួន១៤.៦២៤នាក់ ទទួលបានបណ្ណសម្គាល់ជនមានពិការភាព
- ចុះឈ្មោះជនមានពិការភាពចំនួន៣.៣០៤នាក់ សម្រាប់កម្មវិធីកិច្ចគាំពារសង្គម «កញ្ចប់គ្រួសារ»
- គាំទ្រការតែងតាំងជនមានពិការភាពចំនួន១២៥នាក់ នៅក្នុង គ.ក.ន.ក នៅក្នុងឃុំចំនួន១០៩

ផ្នែកការស្តារលទ្ធភាពពលកម្ម

គាំទ្រផ្នែកPT ដែលទើបត្រូវបានបង្កើតឡើងថ្មីនៅមន្ទីរពេទ្យបង្អែកខេត្ត បានផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនដល់អតិថិជនចំនួន១.៩៥៧នាក់ ចាប់តាំងពីការចាប់ផ្តើមដំណើរការកាលពីខែមិថុនា ឆ្នាំ២០២៥។



> កម្មវិធី ACCESS 2 បានគាំទ្រដល់ការពង្រឹងការរៀបចំផែនការ និងការបែងចែកថវិកាដែលមានលក្ខណៈបរិយាបន្នពិការភាព និងយកចិត្តទុកដាក់លើផ្នែក GBV នៅក្នុងខេត្តកំពង់ចាម ដោយធានាថា តម្រូវការរបស់ក្រុមងាយរងគ្រោះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងផែនការអភិវឌ្ឍន៍មូលដ្ឋាន ការវិនិយោគ និងសេវាចាំបាច់។
>
> **លោកជំទាវ ប៉ាង ដានី អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ចាម**

អគារ ANINA ជាន់ទី៣ ផ្លូវ២៧១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

info@access2cambodia.org www.access2cambodia.org

ACCESS 2 ត្រូវបានគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី និងគ្រប់គ្រងដោយ Abt Global